**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ៨៤ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## គោលការណ៍ណែនាំសម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៤ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ១៤៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការកែសម្រួល

អនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្ដីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម

- បានឃើញអនុក្រឹត្យលេខ១៦០ អនក្រ.បក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២ ស្ដីពីនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលដៅកំណត់នូវគោលការណ៍ណែនាំសម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម ដើម្បីធានាបាននូវប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពរឹងមាំផ្នែកហិរញ្ញវត្ថុ។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការវិនិយោគនៃមូលនិធិសន្តិសុខសង្គម ស្ថិតនៅក្រោមច្បាប់ស្ដីពីរបបសន្តិសុខសង្គម និងច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀតជាធរមាន។

**មាត្រា៣ .-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចខាងក្រោម៖

១. **កញ្ចប់វិនិយោគ** សំដៅដល់បណ្ដុំទ្រព្យសកម្មដែលមានដូចជា៖ ប្រាក់បញ្ញើនៅគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ការវិនិយោគលើមូលបត្រ វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរដ្ឋ និងការអភិវឌ្ឍភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ និងទ្រព្យដែលវិនិយោគលើអចលនទ្រព្យ នៃមូលនិធិវិនិយោគតាមផ្នែក និងវិស័យនីមួយៗនៃប្រព័ន្ធសន្តិសុខសង្គម

២. **ផលិតកានីយកម្មហានិភ័យ** សំដៅដល់ការកំណត់ និងបែងចែកកញ្ចប់វិនិយោគនៃមូលនិធិសន្តិសុខសង្គម ដោយថ្លឹងថ្លែងរវាងកម្រិតហានិភ័យ និងសក្ដានុពលចំណូលពីការវិនិយោគ ដើម្បីសម្រេចឱ្យបាននូវសមិទ្ធផលតាមគោលដៅកំណត់

៣. **ទំនាស់ផលប្រយោជន៍** សំដៅដល់ផលប្រយោជន៍ជាទឹកប្រាក់ ផលប្រយោជន៍នយោបាយ ផលប្រយោជន៍សម្រាប់គ្រួសារ ឬផលប្រយោជន៍ផ្ទាល់ខ្លួន ដែលអាចមានឥទ្ធិពលទៅលើទង្វើរបស់ជនណាម្នាក់ ក្នុងការអនុវត្តកាតព្វកិច្ចជាផ្លូវការរបស់ខ្លួន

៤. **បុគ្គលមានជំនាញវិជ្ជាជីវៈគ្រប់គ្រងការវិនិយោគ** សំដៅដល់បុគ្គលគ្រប់គ្រងមូលនិធិវិនិយោគ ឬក្រុមហ៊ុនបរធនបាលដែលទទួលបានអាជ្ញាបណ្ណពីនិយ័តករពាក់ព័ន្ធ

៥. **ប្រតិបត្តិកររក្សាទុក ឬរក្សាសុវត្ថិភាព** សំដៅដល់ក្រុមហ៊ុនផ្ដល់សេវារក្សាទុកឬរក្សាសុវត្ថិភាពដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពីនិយ័តករពាក់ព័ន្ធ

៦. **ប្រាក់ត្រៀមបម្រុង** សំដៅដល់ប្រាក់ត្រៀមបម្រុងតាមផ្នែកនីមួយៗ នៃរបបសន្តិសុខសង្គម ដូចមានចែងក្នុងមាត្រា២៤, មាត្រា៤៤ និងមាត្រា៦៣ នៃច្បាប់ស្ដីពីរបបសន្តិសុខសង្គម

៧. **ផែនការវិនិយោគ** សំដៅដល់ឯកសារប្រចាំឆ្នាំ ដែលកំណត់នូវយុទ្ធសាស្ត្រ និងសមិទ្ធកម្មគោលដៅ ផ្អែកលើបញ្ហាប្រឈមហានិភ័យនិងធនធាន ដើម្បីសម្រេចបានផលរយៈពេលវែង

៨. **មូលនិធិវិនិយោគ** សំដៅដល់មូលនិធិសន្តិសុខសង្គមប្រើប្រាស់សម្រាប់ការវិនិយោគ ដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៩. **មន្ត្រីបន្ថោល** សំដៅដល់មន្ត្រីដែលមានចំណេះដឹង និងជំនាញវិជ្ជាជីវៈចូលរួមក្នុងការគ្រប់គ្រង និងចាត់ចែងការងារវិនិយោគ

១០. **មូលបត្រ** សំដៅដល់មូលបត្របំណុលរដ្ឋ មូលបត្រកម្មសិទ្ធិ មូលបត្របំណុលឯកជន ឬសញ្ញាបណ្ណសាជីវកម្ម សញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម និងសញ្ញាបណ្ណនិរន្តរភាព។

## ជំពូកទី២

## ប្រភពធនធាននៃមូលនិធិវិនិយោគ

**មាត្រា៤ .-**

មូលនិធិវិនិយោគមានប្រភពមកពី៖

- មូលនិធិសល់ពីប្រាក់ត្រៀមបម្រុងនៃផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម
- ផលចំណេញពីការវិនិយោគ។

មូលនិធិវិនិយោគខាងលើ ត្រូវរក្សាទុកនៅគណនីធនាគារពាណិជ្ជ ដែលជាប្រតិបត្តិកររក្សាទុក ឬរក្សាសុវត្ថិភាព ដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពីនិយ័តករពាក់ព័ន្ធ និងដែលមានទីតាំងស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គណនីមូលនិធិវិនិយោគត្រូវដាក់ដោយឡែកពីគណនីប្រតិបត្តិការផ្សេងទៀត។

**មាត្រា៥ .-**

ផលចំណេញពីការវិនិយោគមូលនិធិសន្តិសុខសង្គមអាចត្រូវបង្គរទុកក្នុងមូលនិធិវិនិយោគដើម្បីធ្វើការវិនិយោគបន្តក្នុងឆ្នាំបន្ទាប់។

គោលការណ៍នៃការប្រើប្រាស់ផលចំណេញពីការវិនិយោគត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលសរសេរជាអក្សរកាត់ថា **អ.ស.ហ.**។

## ជំពូកទី៣

## គោលការណ៍នៃការគ្រប់គ្រងមូលនិធិ

**មាត្រា៦ .-**

បេឡាជាតិសន្តិសុខសង្គម ដែលសរសេរជាអក្សរកាត់ថា **ប.ស.ស.** ត្រូវរៀបចំ និងដាក់ជូននិយ័តករសន្តិសុខសង្គម ដែលសរសេរជាអក្សរកាត់ថា **ន.ស.ស.** នូវគោលការណ៍នៃការគ្រប់គ្រងមូលនិធិសម្រាប់ការវិនិយោគ ដោយមានធាតុអប្បបរមាដូចខាងក្រោម៖

១. គោលបំណង និងគោលដៅនៃការវិនិយោគ

២. អភិបាលកិច្ច

៣. កញ្ចប់វិនិយោគ

៤. ការចាត់ចែងការវិនិយោគ

៥. ការគ្រប់គ្រងហានិភ័យ

៦. ការតាមដាន និងវាយតម្លៃសមិទ្ធកម្ម

៧. ការគ្រប់គ្រងចំណាយនៃការវិនិយោគ

៨. ការរាយការណ៍

៩. ក្រមសីលធម៌វិជ្ជាជីវៈ និងការការពារទំនាស់ផលប្រយោជន៍

១០. ធាតុផ្សេងទៀតដែលកំណត់ដោយ **ន.ស.ស.**។

**ប.ស.ស.** ត្រូវស្នើសុំការឯកភាពពី **ន.ស.ស.** និងស្នើសុំការសម្រេចចុងក្រោយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើគោលការណ៍នៃការគ្រប់គ្រងមូលនិធិសម្រាប់ការវិនិយោគ មុននឹងចាប់ផ្ដើមធ្វើការវិនិយោគមូលនិធិសន្តិសុខសង្គម។

**មាត្រា៧ .-**

**ប.ស.ស.** ត្រូវដាក់មូលនិធិវិនិយោគឱ្យដាច់ដោយឡែកពីគ្នាតាមផ្នែកនិងវិស័យនីមួយៗ។

## ជំពូកទី៤
## ការគ្រប់គ្រងការវិនិយោគ
### ផ្នែកទី១
### ផែនការវិនិយោគ

**មាត្រា៨ .-**

**ប.ស.ស.** ត្រូវរៀបចំផែនការវិនិយោគប្រចាំឆ្នាំសម្រាប់ឆ្នាំបន្ទាប់ យ៉ាងយូរបំផុតត្រឹមថ្ងៃទី១ ខែតុលា ជារៀងរាល់ឆ្នាំ ដើម្បីស្នើសុំការឯកភាពពី **ន.ស.ស.**។ **ន.ស.ស.** ត្រូវឆ្លើយតប ក្នុងរយៈពេល ១(មួយ)ខែ បន្ទាប់ពីទទួលបានការស្នើសុំ និងឯកសារភ្ជាប់ពេញលេញពី **ប.ស.ស.**។

បន្ទាប់ពីទទួលបានការឯកភាពពី **ន.ស.ស.** **ប.ស.ស.** ត្រូវស្នើសុំការសម្រេចចុងក្រោយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ផែនការវិនិយោគត្រូវមានធាតុអប្បបរមាដូចខាងក្រោម៖

១. ទិដ្ឋភាពទូទៅនៃសេដ្ឋកិច្ចសកល និងចក្ខុវិស័យនៃការវិនិយោគ ឬនៃទីផ្សារ

២. យុទ្ធសាស្ត្រនៃការវិនិយោគ

- ទំហំមូលនិធិវិនិយោគ
- កំណើននៃមូលនិធិវិនិយោគរំពឹងទុក
- ផលចំណេញ ចំណាយប្រតិបត្តិការ និងហានិភ័យរំពឹងទុក
- ប្រភេទទ្រព្យសកម្មដែលត្រូវវិនិយោគ

៣. ធាតុផ្សេងទៀតដែលកំណត់ដោយ **ន.ស.ស.**។

### ផ្នែកទី២
### កញ្ចប់វិនិយោគ

**មាត្រា៩ .-**

**ប.ស.ស.** ត្រូវបានអនុញ្ញាតឱ្យវិនិយោគមូលនិធិវិនិយោគប្រចាំឆ្នាំ លើទ្រព្យសកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមទៅតាមការបែងចែកកញ្ចប់វិនិយោគ ដូចខាងក្រោម ៖

១. បញ្ញើនៅគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ចាប់ពី ០(សូន្យ)ភាគរយ រហូតដល់ ៨០ (ប៉ែតសិប)ភាគរយ នៃមូលនិធិវិនិយោគនីមួយៗ
២. វិនិយោគលើមូលបត្រ ចាប់ពី០(សូន្យ)ភាគរយ រហូតដល់ ៨០(ប៉ែតសិប)ភាគរយ នៃមូលនិធិវិនិយោគនីមួយៗ
៣. វិនិយោគផ្ទាល់លើហេដ្ឋារចនាសម្ព័ន្ធរដ្ឋ និងគម្រោងវិនិយោគសាធារណៈក្នុងទម្រង់ភាពជាដៃគូរវាងរដ្ឋ និងឯកជន ចាប់ពី ០(សូន្យ)ភាគរយ រហូតដល់ ២០(ម្ភៃ)ភាគរយ នៃមូលនិធិវិនិយោគនីមួយៗ
៤. វិនិយោគលើអចលនទ្រព្យ ចាប់ពី ០(សូន្យ)ភាគរយ រហូតដល់ ២០(ម្ភៃ)ភាគរយ នៃមូលនិធិវិនិយោគនីមួយៗ។

ចំពោះការវិនិយោគជាក់ស្តែងលើទ្រព្យសកម្មដូចមានចែងក្នុងចំណុច ៣ និង ៤ នៃមាត្រានេះ **ប.ស.ស.** ត្រូវស្នើសុំការសម្រេចជាមុនពី **ន.ស.ស.**។

ការវិនិយោគលើប្រភេទទ្រព្យសកម្មផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាមការសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា១០ .-**

ការវិនិយោគមូលនិធិសន្តិសុខសង្គមនៅក្រៅប្រទេស អាចអនុវត្តបានតែចំពោះមូលបត្របំណុល និងមិនត្រូវឱ្យលើសពី ២០(ម្ភៃ)ភាគរយ នៃមូលនិធិវិនិយោគតាមផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម។

**មាត្រា១១ .-**

កញ្ចប់វិនិយោគលើទ្រព្យសកម្មនីមួយៗ ដូចមានចែងក្នុងមាត្រា៩ និងមាត្រា១០ នៃអនុក្រឹត្យនេះ ជាកម្មវត្ថុនៃការអនុវត្តវិធានប្រុងប្រយ័ត្ន ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

**មាត្រា១២ .-**

**ប.ស.ស.** ត្រូវរៀបចំថវិកានីយកម្មហានិភ័យសម្រាប់ការវិនិយោគ ដែលរួមបញ្ចូលនូវៈ
១. កម្រិតហានិភ័យដែលអាចទទួលយកបាន ដើម្បីសម្រេចគោលដៅនៃផលចំណេញ
២. ផលចំណេញរំពឹងទុកសម្រាប់ឯកតាហានិភ័យនីមួយៗ
៣. ភាពទាក់ទាញនៃឱកាសវិនិយោគ គំនិតផ្តួចផ្តើមវិនិយោគ ប្រភេទទ្រព្យសកម្ម និងបុគ្គលមានជំនាញវិជ្ជាជីវៈគ្រប់គ្រងការវិនិយោគ។

ក្នុងករណីចាំបាច់ **ន.ស.ស.** មានសិទ្ធិតម្រូវឱ្យ **ប.ស.ស.** ធ្វើការកែសម្រួលកញ្ចប់វិនិយោគផ្អែកលើថវិកានីយកម្មហានិភ័យ។

**មាត្រា១៣ .-**

**ប.ស.ស.** ត្រូវធ្វើការវាយតម្លៃសមិទ្ធកម្មនៃការវិនិយោគប្រចាំឆ្នាំ ដោយធៀបទៅនឹងសូចនាករ និងគោលដៅនៃផលចំណេញពីវិនិយោគ ដែលបានស្នើក្នុងផែនការវិនិយោគ និងត្រូវដាក់ជូន **ន.ស.ស.** យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់ ដើម្បីពិនិត្យ និងផ្តល់យោបល់។

**ប.ស.ស.** ត្រូវធ្វើការព្យាករសមិទ្ធកម្មកញ្ចប់វិនិយោគសម្រាប់រយៈពេល ៣(បី)ឆ្នាំរំកិល និង

ត្រូវដាក់ជូន **ន.ស.ស.** យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់ ដើម្បីពិនិត្យ និងផ្តល់យោបល់។

## ជំពូកទី៥
## ការចាត់ចែង និងការគ្រប់គ្រងការវិនិយោគ

**មាត្រា១៤ .-**

ការចាត់ចែង និងការគ្រប់គ្រងការវិនិយោគរបស់ផ្នែកនីមួយៗនៃរបបសន្តិសុខសង្គមត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ **ប.ស.ស.** ដែលជាសេនាធិការរបស់ **ប.ស.ស.** លើផ្នែកវិនិយោគមូលនិធិសន្តិសុខសង្គម។

ក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ **ប.ស.ស.** ត្រូវមានចំនួនសមាជិកសមស្រប ដែលក្នុងនោះត្រូវមានសមាជិកឯករាជ្យយ៉ាងតិច ២(ពីរ)រូប។ សមាជិកឯករាជ្យ ត្រូវមានការទទួលស្គាល់ពី **ន.ស.ស.**។ **ន.ស.ស.** មានសិទ្ធិតម្រូវឱ្យកែសម្រួលសមាសភាពសមាជិកក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ **ប.ស.ស.** ក្នុងករណីមិនបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១. មានលក្ខណសម្បត្តិ និងអត្តចរិតល្អ និងមិនត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ
២. ជាសមត្ថជនមានអាយុចាប់ពី ៣៥(សាមសិបប្រាំ)ឆ្នាំឡើងទៅ និងមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា
៣. ត្រូវមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ ពាក់ព័ន្ធនឹងជំនាញគណនេយ្យ ធនាគារ ហិរញ្ញវត្ថុ សវនកម្ម វិនិយោគ ការគណនាវាយតម្លៃ ឬសញ្ញាបត្រសមមូលផ្សេងទៀត
៤. ត្រូវមានបទពិសោធន៍ការងារយ៉ាងតិច ៥(ប្រាំ)ឆ្នាំ ក្នុងវិស័យ ធនាគារ ហិរញ្ញវត្ថុ ឬវិនិយោគ
៥. មិនត្រូវមានទំនាស់ផលប្រយោជន៍ជាមួយគម្រោងវិនិយោគណាមួយរបស់ **ប.ស.ស.**។

ចំនួនសមាជិក និងលក្ខខណ្ឌតម្រូវនៃក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ **ប.ស.ស.** អាចត្រូវបានកែសម្រួលតាមការចាំបាច់ស្របតាមបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា១៥ .-**

សមាជិកឯករាជ្យត្រូវបានជ្រើសរើសដោយគិតគូរលើលក្ខខណ្ឌបន្ថែមដូចខាងក្រោម៖

១. មិនជាប់ពាក់ព័ន្ធក្នុងការងារ ដោយផ្ទាល់ ឬដោយប្រយោលជាមួយ **ប.ស.ស.** ក្នុងរយៈពេល ១(មួយ)ឆ្នាំ ចុងក្រោយ
២. មិនត្រូវមានទំនាស់ផលប្រយោជន៍ជាមួយ **ន.ស.ស.** និង **ប.ស.ស.** ឬជាមួយថ្នាក់ដឹកនាំរបស់ **ន.ស.ស.** និង **ប.ស.ស.**
៣. មិនមានសមាជិកនៅក្នុងបន្ទុកគ្រួសារ ដែលបាន និងកំពុងធ្វើជាប្រធាន ឬសមាជិកនៃក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំរបស់បេឡាជាតិសន្តិសុខសង្គម ឬថ្នាក់ដឹកនាំរបស់ **ន.ស.ស.** នៅក្នុងរយៈពេល ១(មួយ)ឆ្នាំ ចុងក្រោយ
៤. លក្ខខណ្ឌតម្រូវផ្សេងទៀតដែលកំណត់ដោយ **ន.ស.ស.**។

**មាត្រា១៦ .-**

**ប.ស.ស.** ត្រូវបង្កើតអង្គភាពវិនិយោគ ជាសេនាធិការដើម្បីទទួលបន្ទុកការងារចាត់ចែង

និងគ្រប់គ្រងការវិនិយោគ។

អង្គភាពវិនិយោគ ត្រូវមានមន្ត្រីបង្គោល ដែលបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. មានលក្ខណសម្បត្តិ និងអត្តចរិតល្អ និងមិនត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

២. ជាសមត្ថជន និងមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា

៣. បំពេញលក្ខខណ្ឌយ៉ាងហោចណាស់មួយក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោម៖

ក. ជាគណនេយ្យករជំនាញ (Certified Public Accountant) ឬជាអ្នកវិភាគហិរញ្ញវត្ថុជំនាញ (Chartered Financial Analyst)

ខ. បានបញ្ចប់កម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ (Certified Accounting Technician) ឬប្រឡងជាប់កម្រិតទី១ នៃកម្មវិធីអ្នកវិភាគហិរញ្ញវត្ថុជំនាញ (Chartered Financial Analyst) និងមានបទពិសោធន៍ការងារយ៉ាងតិចរយៈពេល ៣(បី)ឆ្នាំ ក្នុងវិស័យធនាគារ ហិរញ្ញវត្ថុ ឬវិនិយោគ

គ. មានសញ្ញាបត្រ ចាប់ពីកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែលឡើងទៅ និងមានបទពិសោធន៍ការងារយ៉ាងតិចរយៈពេល ៥(ប្រាំ)ឆ្នាំ ក្នុងវិស័យធនាគារ ហិរញ្ញវត្ថុ ឬវិនិយោគ។

មន្ត្រីបង្គោលនៃអង្គភាពវិនិយោគ ត្រូវជាមន្ត្រីដែលបំពេញការងារពេញម៉ោងក្នុងការងារផ្នែកវិនិយោគមូលនិធិសន្តិសុខសង្គម។

លក្ខខណ្ឌតម្រូវនៃមន្ត្រីបង្គោល អាចត្រូវបានកែសម្រួលតាមការចាំបាច់។

**មាត្រា១៧ .-**

**ប.ស.ស.** អាចចាត់ចែងការវិនិយោគដោយផ្ទាល់ ឬជ្រើសរើសបុគ្គលមានជំនាញវិជ្ជាជីវៈគ្រប់គ្រងការវិនិយោគឱ្យទទួលខុសត្រូវអនុវត្តប្រតិបត្តិការវិនិយោគលើប្រភេទឧបករណ៍វិនិយោគណាមួយ។

**មាត្រា១៨ .-**

ក្នុងករណីជ្រើសរើសបុគ្គលមានជំនាញវិជ្ជាជីវៈគ្រប់គ្រងការវិនិយោគឱ្យទទួលខុសត្រូវអនុវត្តប្រតិបត្តិការវិនិយោគ **ប.ស.ស.** ត្រូវប្រើប្រាស់ដំណើរការជ្រើសរើសដោយប្រកួតប្រជែង។

បុគ្គលមានជំនាញវិជ្ជាជីវៈគ្រប់គ្រងការវិនិយោគដែលត្រូវបានជ្រើសរើស មានកាតព្វកិច្ចរាយការណ៍ជូន **ន.ស.ស.** នូវសកម្មភាពពាក់ព័ន្ធនឹងការវិនិយោគមូលនិធិសន្តិសុខសង្គម។

លក្ខខណ្ឌ ប្រភេទ និងទម្រង់នៃរបាយការណ៍ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ **ន.ស.ស.**។

**មាត្រា១៩ .-**

**ប.ស.ស.** ត្រូវរក្សាទុកទ្រព្យសកម្មនៃមូលនិធិវិនិយោគតាមផ្នែកនីមួយៗនៃរបបសន្តិសុខសង្គមទៅក្នុងគណនីរក្សាសុវត្ថិភាព ជាមួយប្រតិបត្តិកររក្សាទុក ឬរក្សាសុវត្ថិភាព។

ប្រតិបត្តិកររក្សាទុក ឬរក្សាសុវត្ថិភាព មានកាតព្វកិច្ចរាយការណ៍ជូន **ន.ស.ស.** នូវសកម្មភាពពាក់ព័ន្ធនឹងការរក្សាទុក ឬរក្សាសុវត្ថិភាពនៃការវិនិយោគមូលនិធិសន្តិសុខសង្គម។

លក្ខខណ្ឌ ប្រភេទ និងទម្រង់នៃរបាយការណ៍ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ **ន.ស.ស.**។

## ជំពូកទី៦
## ការវាយតម្លៃទ្រព្យសកម្ម

**មាត្រា២០ .-**

**ប.ស.ស.** ត្រូវវាយតម្លៃប្រចាំឆ្នាំលើទ្រព្យសកម្មនៃមូលនិធិសន្តិសុខសង្គម និងផ្តល់របាយការណ៍ជូន **ន.ស.ស.** ក្នុងរយៈពេលយ៉ាងយូរ មុនដំណាច់ឆមាសទី១ នៃឆ្នាំបន្ទាប់។

**ន.ស.ស.** អាចតម្រូវឱ្យ **ប.ស.ស.** ជ្រើសរើសក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ និងអ្នកវាយតម្លៃឯករាជ្យឱ្យធ្វើការវាយតម្លៃលើទ្រព្យសកម្មនៃមូលនិធិសន្តិសុខសង្គមតាមការចាំបាច់។

**មាត្រា២១ .-**

រាល់កិច្ចប្រតិបត្តិការរបស់ **ប.ស.ស.** ជាមួយស្ថាប័ន ក្រុមហ៊ុន និងភ្នាក់ងារ ផ្សេងទៀតដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការវិនិយោគ ត្រូវស្នើសុំការអនុញ្ញាតជាមុនពី **ន.ស.ស.**។

## ជំពូកទី៧
## ការផ្តល់របាយការណ៍ និងការជូនដំណឹងករណីគ្រោះអាសន្ន

**មាត្រា២២ .-**

**ប.ស.ស.** ត្រូវផ្តល់របាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូន **ន.ស.ស.**។

ប្រភេទ និងទម្រង់នៃរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ និងរបាយការណ៍ផ្សេងទៀត ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ **ន.ស.ស.**។

**មាត្រា២៣ .-**

**ប.ស.ស.** ត្រូវជូនដំណឹងភ្លាមដល់ **ន.ស.ស.** ក្នុងករណីមានគ្រោះអាសន្ន ឬការប្រែប្រួលណាមួយដែលអាចជះឥទ្ធិពលដល់ភាពរឹងមាំផ្នែកហិរញ្ញវត្ថុនៃមូលនិធិវិនិយោគ ព្រមទាំងសកម្មភាពឬវិធានការទាំងអស់ដែល **ប.ស.ស.** ត្រូវធ្វើឡើងដើម្បីគ្រប់គ្រងការប្រែប្រួលនោះ។

លក្ខណៈវិនិច្ឆ័យនៃភាពរឹងមាំផ្នែកហិរញ្ញវត្ថុនៃមូលនិធិវិនិយោគ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

## ជំពូកទី៨
## ទណ្ឌកម្ម

**មាត្រា២៤ .-**

បុគ្គល និងតួអង្គពាក់ព័ន្ធ ដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យ និងទោស ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា២៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

## ជំពូកទី៦

## ការវាយតម្លៃទ្រព្យសកម្ម

**មាត្រា២០ .-**

**ម.ស.ស.** ត្រូវវាយតម្លៃប្រចាំឆ្នាំលើទ្រព្យសកម្មនៃមូលនិធិសន្តិសុខសង្គម និងផ្តល់របាយការណ៍ជូន **ន.ស.ស.** ក្នុងរយៈពេលយ៉ាងយូរ មុនដំណាច់ឆមាសទី១ នៃឆ្នាំបន្ទាប់។

**ន.ស.ស.** អាចតម្រូវឱ្យ **ម.ស.ស.** ជ្រើសរើសក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ និងអ្នកវាយតម្លៃឯករាជ្យឱ្យធ្វើការវាយតម្លៃលើទ្រព្យសកម្មនៃមូលនិធិសន្តិសុខសង្គមតាមការចាំបាច់។

**មាត្រា២១ .-**

រាល់កិច្ចប្រតិបត្តិការរបស់ **ម.ស.ស.** ជាមួយស្ថាប័ន ក្រុមហ៊ុន និងភ្នាក់ងារ ផ្សេងទៀតដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការវិនិយោគ ត្រូវស្នើសុំការអនុញ្ញាតជាមុនពី **ន.ស.ស.**។

## ជំពូកទី៧

## ការផ្តល់របាយការណ៍ និងការជូនដំណឹងករណីគ្រោះអាសន្ន

**មាត្រា២២ .-**

**ម.ស.ស.** ត្រូវផ្តល់របាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូន **ន.ស.ស.**។

ប្រភេទ និងទម្រង់នៃរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ និងរបាយការណ៍ផ្សេងទៀត ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ **ន.ស.ស.**។

**មាត្រា២៣ .-**

**ម.ស.ស.** ត្រូវជូនដំណឹងភ្លាមដល់ **ន.ស.ស.** ក្នុងករណីមានគ្រោះអាសន្ន ឬការប្រែប្រួលណាមួយដែលអាចជះឥទ្ធិពលដល់ភាពរឹងមាំផ្នែកហិរញ្ញវត្ថុនៃមូលនិធិវិនិយោគ ព្រមទាំងសកម្មភាព ឬវិធានការទាំងអស់ដែល **ម.ស.ស.** ត្រូវធ្វើឡើងដើម្បីគ្រប់គ្រងការប្រែប្រួលនោះ។

លក្ខណៈវិនិច្ឆ័យនៃភាពរឹងមាំផ្នែកហិរញ្ញវត្ថុនៃមូលនិធិវិនិយោគ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

## ជំពូកទី៨

## ទណ្ឌកម្ម

**មាត្រា២៤ .-**

បុគ្គល និងតួអង្គពាក់ព័ន្ធ ដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យ និងទោស ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

**មាត្រា២៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៦ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១០កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ